MASSACHUSETTS DEPARTMENT OF EDUCATION

MASSACHUSETTS COMPREHENSIVE ASSESSMENT SYSTEM

*ប្រព័ន្ធការប៉ាន់ប្រមាណទូលំទូលាយ*
*នៃរដ្ឋម៉ាស្យាឈូសិត*
*(MCAS)*

# សេចក្តីណែនាំសម្រាប់មាតាបិតា និង អាណាព្យាបាល ស្តីពី **2006 MCAS**

ក្រសួងសិក្សាធិការ រដ្ឋម៉ាស្យាឈូសិត

# ក្រសួងសិក្សាធិការរដ្ឋម៉ាសាឈូសិត

*ឯកសារនេះត្រូវបានរៀបចំឡើងដោយក្រសួងសិក្សាធិការរដ្ឋម៉ាសាឈូសិត*
Dr. David P. Driscoll, ស្នងការក្រសួងសិក្សាធិការ

## *បុព្វកថានៃស្នងការក្រសួងសិក្សាធិការ*

សូមជម្រាបចំពោះមាតាបិតា ឬ អាណាព្យាបាលជាទីមេត្រី !

ការប្រឡងMCAS ជាផ្នែកសំខាន់មួយនៃការខំប្រឹងប្រែងរបស់រដ្ឋយើង ដើម្បីពង្រឹងពង្រីកការចេះដឹងរបស់សិស្សានុសិស្សក្នុងរដ្ឋម៉ាសាឈូសិត ។ ការប្រឡងទាំងអស់ រៀបចំឡើងដើម្បីប្រមាណអំពីកម្រិតជំនាញសំខាន់ៗ និង ចំណេះចេះដឹងនូវមុខវិជ្ជាមួយចំនួនដែលជាមូលដ្ឋាននៃការសិក្សា ។

សេចក្តីណែនាំនេះរៀបចំឡើងដើម្បីជួយលោក–អ្នកក្នុងការរៀបចំពិនិត្យពិនិត្យមើលឡើងវិញនូវលទ្ធផលនៃការប្រឡងMCAS របស់កូនលោក–អ្នកនៅរដូវផ្ការីកឆ្នាំ 2006 ហើយនិងក្នុងការយល់ដឹងនូវរបៀបរាយការណ៍អំពីពិន្ទុរបស់MCAS ។ សេចក្តីណែនាំនេះផ្តល់ព័ត៌មានជាបន្ថែមទៅលើដំណឹងនៅក្នុង *Parent / Guardian Report [ សេចក្តីណែនាំសម្រាប់មាតាបិតា និង អាណាព្យាបាល ]* របស់កូនលោក–អ្នក ។ ឆ្នាំនេះ សេចក្តីណែនាំសម្រាប់មាតាបិតា និង អាណាព្យាបាល ត្រូវបានពង្រីកដើម្បីបញ្ចូលព័ត៌មានបន្ថែមស្តីពីលទ្ធផលការប្រឡងសម្រាប់សិស្សគ្រប់កម្រិតថ្នាក់ទាំងអស់ ។ ខ្ញុំសង្ឃឹមថា លោក–អ្នកនឹងមើលឃើញនូវព័ត៌មានដ៏មានប្រយោជន៍នេះ ។

បើសិនជាលោក–អ្នក មានសំណួរផ្សេងៗថែមទៀត ស្តីពីអត្ថន័យនៃលទ្ធផល ឬ កម្រិតការសិក្សារបស់កូន លោក–អ្នក ខ្ញុំសូមលើកទឹកចិត្តលោក–អ្នក ឱ្យអញ្ជើញទៅជួបគ្រូៗរបស់កូនលោក–អ្នក ដើម្បីពិភាក្សាពីលទ្ធផលទាំងនោះ ហើយនិងរិះរកមធ្យោបាយយ៉ាងណា ដែលអាចឱ្យលោក–អ្នកធ្វើសហការជាមួយសាលាដើម្បី ជួយដល់ការសិក្សារបស់កូនលោក–អ្នក ។ ជំនួយរបស់លោក–អ្នកគឺមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការជួយកូនរបស់លោក–អ្នក ឱ្យបានសម្រេចជោគជ័យនៅសាលារៀន ក្នុងការពង្រឹងការអប់រំសម្រាប់សិស្សានុសិស្សនៃរដ្ឋម៉ាសាឈូសិត ។

ដោយសេចក្តីស្មោះស្ម័គ្រ !

**David P. Driscoll**
ស្នងការក្រសួងសិក្សាធិការ

Copyright © 2006 Massachusetts Department of Education
តាមរយៈនេះ ការអនុញ្ញាតឱ្យចម្លងផ្នែកខ្លះ ឬ គ្រប់ផ្នែកទាំងអស់នៃឯកសារនេះ សម្រាប់គោលបំណងអប់រំ មិនមានលក្ខណៈពាណិជ្ជកម្ម ។ សូមផ្តល់កិត្តិយសចំពោះ **“Massachusetts Department of Education”** ។

**ឯកសារនេះ បានបោះពុម្ពដោយប្រើក្រដាសយកប្រើម្តងទៀត**

350 Main Street, Malden, Massachusetts 02148-5023
781-338-3000
www.doe.mass.edu

# មាតិការឿង

*បុព្វកថានៃស្នងការក្រសួងសិក្សាធិការ*


**I. តើគោលបំណងរបស់ MCAS ប្រព័ន្ធការប៉ាន់ប្រមាណទូលំទូលាយនៃរដ្ឋម៉ាស្សាឈូសិតមានអ្វីខ្លះ ?** ........ 2
សេចក្តីណែនាំស្តីអំពីការចូលរួម ........ 2
សិស្សដែលរៀនធ្លាក់ ........ 2
សិស្សមានជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់ (LEP) ........ 3

**II. តើមុខវិជ្ជាអ្វីខ្លះដែលបានសួរពិនិត្យក្នុងការប្រឡង MCAS / សំណួរសាកល្បងនៅរដូវផ្ការីក ឆ្នាំ 2006 នេះ ?** ........ 4
សំណួរសាកល្បង ........ 5
ការប្រឡងសារជាថ្មី ........ 5

**III. តើសំណួរប្រភេទអ្វីខ្លះ ដែលមាននៅក្នុងការប្រឡង MCAS ?** ........ 5

**IV. តើគេនឹងប្រើប្រាស់លទ្ធផលការប្រឡងរបស់កូនខ្ញុំយ៉ាងដូចម្តេច ?** ........ 6

**V. តើលទ្ធផលនៃ MCAS រាយការណ៍យ៉ាងដូចម្តេច ?** ........ 8
ក. ពិន្ទុរបស់កូនលោក-អ្នក ........ 8
កម្រិតលទ្ធផលនៃការប្រឡង ........ 8
មាត្រដ្ឋានពិន្ទុ ........ 8
ពិន្ទុសុទ្ធ ........ 9
ការបង្ហាញពិន្ទុ និង លំដាប់ពិន្ទុ ........ 9
ខ. ផ្នែកទី II : (ថ្នាក់ទី 4 ទី 7 និង ទី 10) យោបល់ស្តីពីការបំពេញកិច្ចការផ្នែកសរសេររបស់កូនលោក-អ្នក ........ 9
គ. ផ្នែកទី III : ព័ត៌មានពីពិន្ទុរបស់កូនលោក-អ្នកចំពោះសំណួរសាកល្បងរបស់ MCAS ........ 10
ឃ. ផ្នែកទី IV : តើពិន្ទុរបស់កូនលោក-អ្នក ប្រៀបធៀបទៅនឹងពិន្ទុសាលាមណ្ឌល និង រដ្ឋយ៉ាងដូចម្តេចដែរ ? ........ 10
ង. តើមានន័យយ៉ាងដូចម្តេច បើសិនរបាយការណ៍សម្រាប់មាតាបិតា និង អាណាព្យាបាលបញ្ជាក់ថាកូនខ្ញុំចូលរួមក្នុងការវាយតម្លៃជ្រើសរើស ? ........ 11
ច. ក្នុងលក្ខខណ្ឌបែបណាដែលកូនសិស្សមួយណា មិនបានទទួលពិន្ទុ MCAS ? ........ 11

**VI. តើខ្ញុំអាចរកព័ត៌មានថែមទៀតនៅឯណា ?** ........ 11
ក. របាយការណ៍បន្ថែមដែលអាចមាន ........ 11
ខ. ប្រភពជំនួយផ្សេងទៀត ........ 12
គ. តើខ្ញុំអាចធ្វើអ្វីដើម្បីជួយកូនខ្ញុំ ? ........ 12

# I. តើគោលបំណងរបស់ MCAS ប្រព័ន្ធការប៉ាន់ប្រមាណទូលំទូលាយនៃរដ្ឋម៉ាសាឈូសិតមានអ្វីខ្លះ ?

Massachusetts Comprehensive Assessment System [ ប្រព័ន្ធការប៉ាន់ប្រមាណទូលំទូលាយនៃរដ្ឋម៉ាស្សាឈូសិត ] (MCAS) បានបង្កើតឡើងសម្របតាមការតម្រូវនៃ Education Reform Law [ ច្បាប់កែទម្រង់សិក្សាធិការ ] ឆ្នាំ 1993 ។ ច្បាប់នេះចែងថា កម្មវិធីប្រឡងត្រូវតែ :

- ឱ្យសិស្សានុសិស្សទាំងអស់រៀននៅសាលារដ្ឋនៃរដ្ឋម៉ាស្សាឈូសិតធ្វើការប្រឡង ដោយរាប់បញ្ចូលទាំងសិស្សដែលរៀនធ្លាក់ និង សិស្សមានជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់
- ប៉ាន់ប្រមាណសមត្ថភាពរបស់សិស្សម្នាក់ៗ ដោយអនុលោមទៅតាមលក្ខខណ្ឌសិក្សានៃ *Curriculum Framework [ គំរោងកម្មវិធីសិក្សា ]* នៃរដ្ឋម៉ាស្សាឈូសិត ។
- រាយការណ៍អំពីសមត្ថភាពរបស់សិស្សម្នាក់ៗ សាលារៀននិមួយៗ និង តំបន់និមួយៗ

ដូចបានតម្រូវដោយ Education Reform Law [ ច្បាប់កែទម្រង់សិក្សាធិការ ] សិស្សទាំងឡាយត្រូវតែប្រឡងជាប់ថ្នាក់ទី 10 នៃ English Language Arts [ អក្សរសិល្ប៍អង់គ្លេស ] (ELA) និង គណិតសាស្ត្រ ដែលជាលក្ខខណ្ឌសម្រាប់ជាសិទ្ធិទទួលសញ្ញាប័ត្រមធ្យមសិក្សា (បន្ថែមទៅលើការបំពេញតម្រូវការមូលដ្ឋាន ) ។

ជាងនេះទៅទៀត កម្មវិធីMCASត្រូវបានប្រើប្រាស់ដើម្បីរៀបចំឱ្យសាលា និង តំបន់ទទួលខុសត្រូវជាមូលដ្ឋានប្រចាំឆ្នាំសម្រាប់ការចម្រើនលូតលាស់ដែលគេបានធ្វើឆ្ពោះទៅកាន់គោលដៅនៃ No Child Left Behind Law [ សិស្សណាម្នាក់រៀននៅក្រោយកម្មវិធី ] ថាសិស្សទាំងអស់ត្រូវតែមានចំណេះដឹងគ្រប់គ្រាន់ក្នុងការអាន និង ការធ្វើចំណោទនៅឆ្នាំ 2014 ។

## សេចក្តីណែនាំស្តីអំពីការចូលរួម

នៅក្នុងឆ្នាំ 2006 សិស្សសាលារដ្ឋទាំងអស់ ចាប់ពីថ្នាក់ទី 3 រហូតដល់ថ្នាក់ទី 8 និងថ្នាក់ទី 10 ត្រូវចូលរួមប្រឡង MCAS ។

## សិស្សដែលរៀនធ្លាក់

ក្នុងរយៈពេលមួយឆ្នាំ មុនពេលធ្វើការវាយតម្លៃទូទាំងរដ្ឋដែលបានគ្រោងទុក Individualized Education Program [ កម្មវិធីអប់រំជាលក្ខណៈបុគ្គល ] (IEP) ឬ ក្រុមការងារ 504 បានជួបជុំគ្នា សម្រេចអំពីរបៀបចូលរួមក្នុងការប្រឡង MCAS របស់សិស្សដែលរៀនធ្លាក់ម្នាក់ៗ ។ ព័ត៌មាននេះត្រូវ បានធ្វើជាឯកសារ នៅក្នុង IEP ឬ ផែនការ 504 របស់សិស្ស ។

សម្រាប់សិស្សដែលរៀនធ្លាក់ ដែលមិនអាចប្រឡង MCAS ជាធម្មតាបាន ទោះបីជាមាន ឬ ក៏គ្មានការ សម្របសម្រួលពីសាលាទេ នោះក្រសួងសិក្សាធិការនិងត្រួតពិនិត្យ Alternate Assessment [ ការវាយតម្លៃជម្រើស ] របស់ MCAS ។ ឪពុកម្តាយរបស់សិស្សដែលចូលរួមក្នុងការវាយតម្លៃជម្រើសនឹង ទទួល Parent/ Guardian Reports [ របាយការណ៍សម្រាប់មាតាបិតា និង អាណាព្យាបាល ] ពីរ មួយ ជារបាយការណ៍ធម្មតាដែលបញ្ជាក់ថាសិស្សបានទទួលយកការវាយតម្លៃជម្រើស និង បង្ហាញពីកម្រិតស្នាដៃរបស់សិស្ស និង របាយការណ៍មួយទៀតបង្ហាញពីព័ត៌មានលំអិតពីស្នាដៃរបស់សិស្សលើការវាយតម្លៃជម្រើស ។

លទ្ធផល MCAS របស់សិស្សដែលរៀនធ្លាក់ រួមទាំងសិស្សដែលចូលរួមក្នុងការវាយតម្លៃជម្រើស នឹង ត្រូវបានបញ្ចូលទៅក្នុងលទ្ធផលរបស់សាលា មណ្ឌល និង រដ្ឋ ។

ព័ត៌មានបន្ថែមអំពីសេចក្តីតម្រូវក្នុងការចូលរួមប្រឡង និង លទ្ធភាពផ្សេងៗ ដែលសាលាអាចរៀបចំសម្របសម្រួលបាន អាចរកឃើញនៅក្នុងឯកសារ *Requirements for the Participation of Students with Disabilities in MCAS (Spring 2006 Update) [ តម្រូវការនៃការចូលរួមរបស់សិស្សដែល រៀនធ្លាក់ (កែសម្រួលនានិទាឃរដូវឆ្នាំ 2006)]* ដែលមាននៅលើវិបសាយរបស់ក្រសួងតាមអាសយដ្ឋាន www.doe.mass.edu/mcas/part_req. html ។

## សិស្សមានជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់ (LEP)

Limited English Proficient [ សិស្សមានជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់ ] (LEP) " គឺជាសិស្សដែលមានភាសាកំណើតមិនមែនជាភាសាអង់គ្លេស ដែលពុំអាចបំពេញកិច្ចការសាលាធម្មតាជាភាសាអង់គ្លេសបាន " ។ ការចាត់ទុកសិស្សថា មានលក្ខណៈជាសិស្សមានជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់ (LEP) ត្រូវបានធ្វើឡើងស្របតាមរបៀបសំគាល់លក្ខណៈនៃមណ្ឌល ។

បញ្ញត្តិថ្មីនៃច្បាប់សហព័ន្ធ និង រដ្ឋ តម្រូវថាសិស្ស LEP ទាំងអស់ដែលបានចុះឈ្មោះរៀននៅសាលារដ្ឋនៃរដ្ឋម៉ាស្សាឈូសិត និង នៅសាលាឯកជនដែលរដ្ឋបង់ថ្លៃឱ្យត្រូវតែចូលរួមប្រឡង MCAS ផ្នែក គណិតសាស្ត្រ និង វិទ្យាសាស្ត្រ ព្រមទាំងបច្ចេកវិទ្យា/វិស្វកម្ម ដែលបានផ្តល់តាមកម្រិតថ្នាក់របស់គេ ។ សិស្ស LEP ទាំងអស់ដែលចុះឈ្មោះចូលរៀននៅសាលារដ្ឋ នៅសហរដ្ឋអាមេរិកឆ្នាំដំបូង មានការជ្រើសរើសចូលរួមប្រឡងអក្សរសិល្ប៍អង់គ្លេស (ELA) តាមកម្រិតថ្នាក់របស់គេ ។ មិនតែប៉ុណ្ណោះសោត ពេលបច្ចុប្បន្ននេះ សិស្ស LEP ទាំងអស់ គឺតម្រូវឱ្យចូលរួមប្រឡងភាពជំនាញភាសាអង់គ្លេសប្រចាំឆ្នាំ (MEPA-R/W [ អាន/សរសេរ ] និង MELA-O [ ផ្ទាល់មាត់ ] ) ។

ក្នុងឆ្នាំ 2006 សិស្ស LEP ដែលនិយាយភាសាអេស្ប៉ាញមានសិទ្ធិទទួលបានការចុះឈ្មោះរៀននៅ សហរដ្ឋអាមេរិកចំនួនតិចជាងបីឆ្នាំ មានជម្រើសប្រឡងគណិតសាស្ត្រថ្នាក់ទី 10 ជាពីរភាសាអង់គ្លេស/ភាសាអេស្ប៉ាញ បើគេអាចអាន និង សរសេរភាសាអេស្ប៉ាញស្មើ ឬ ក្បែរនឹងកម្រិតថ្នាក់ ។

ព័ត៌មានបន្ថែមអំពីសេចក្តីណែនាំក្នុងការចូលរួមនៃសិស្ស LEP អាចរកឃើញនៅក្នុងឯកសារ *Requirements for the Participation of Students with Limited English Proficiency in MCAS and MEPA ( Spring 2006 Update ) [ សេចក្តីត្រូវការចូលរួម ប្រឡងនៃសិស្សមានជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់ក្នុង MCAS និង (កែសម្រួលនារដូវផ្ការីកឆ្នាំ 2006) ]* ដែលមាននៅលើវិបសាយរបស់ក្រសួងតាមអាសយដ្ឋាន www.doe.mass.edu/mcas/part_req.html ។

## II. តើមុខវិជ្ជាអ្វីខ្លះដែលបានសួរពិនិត្យក្នុងការប្រឡង MCAS / សំណួរសាកល្បងរដូវផ្ការីកឆ្នាំ 2006 នេះ ?

តារាងខាងក្រោមបង្ហាញពីការប្រឡង MCAS 2006 និង question tryouts [ សំណួរសាកល្បង ] ដែលត្រូវពិនិត្យនៅកម្រិតថ្នាក់និមួយៗ ។

| | |
|---|---|
| ថ្នាក់ទី 3 | Reading [ អំណាន ]<br>Mathematics [ គណិតវិទ្យា ] |
| ថ្នាក់ទី 4 | ELA (Composition; Language and Literature) [តែងសេចក្តី ភាសា និង អក្សរសាស្ត្រ ]<br>គណិតវិទ្យា |
| ថ្នាក់ទី 5 | ELA Language and Literature [ ភាសា និង អក្សរសាស្ត្រ ]<br>គណិតវិទ្យា<br>Science and Technology/Engineering [ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា/វិស្វកម្ម]<br>History and Social Science Question Tryout<br>[ប្រវត្តិវិទ្យា និង ការសាកល្បងសំណួរ វិទ្យាសាស្ត្រសង្គម]* |
| ថ្នាក់ទី 6 | ELA ភាសា និង អក្សរសាស្ត្រ<br>គណិតវិទ្យា |
| ថ្នាក់ទី 7 | ELA (តែងសេចក្តី ភាសា និង អក្សរសាស្ត្រ )<br>គណិតវិទ្យា<br>ប្រវត្តិវិទ្យា និង ការសាកល្បងសំណួរវិទ្យាសាស្ត្រសង្គម * |
| ថ្នាក់ទី 8 | ELA (ភាសា និង អក្សរសាស្ត្រ )<br>គណិតវិទ្យា<br>វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា/វិស្វកម្ម |
| ថ្នាក់ទី 10 | ELA (តែងសេចក្តី ភាសា និង អក្សរសាស្ត្រ )<br>គណិតវិទ្យា |
| ថ្នាក់ទី 9/10 | ប្រឡងវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា/វិស្វកម្ម**<br>● Biology [ ជីវវិទ្យា ]<br>● Chemistry [ គីមីវិទ្យា ]<br>● Introductory Physics [ រូបវិទ្យា ]<br>● Technology/Engineering [ បច្ចេកវិទ្យា និង វិស្វកម្ម ] |
| ថ្នាក់ទី 10/11 | U.S. History Question Tryout [ ការសាកល្បងសំណួរប្រវត្តិសាស្ត្រអាមេរិក ]* |
| Retests [ប្រឡងឡើងវិញ] | ELA (តែងសេចក្តី ភាសា និង អក្សរសាស្ត្រ )<br>គណិតវិទ្យា |

* មិនមានលទ្ធផលកម្រិតរបស់សិស្សត្រូវបានធ្វើឡើង ផ្អែកតាមការសាកល្បងសំណួរ នោះទេ ។

** មិនមានលទ្ធផលកម្រិតរបស់សិស្សត្រូវបានធ្វើឡើងសម្រាប់ការប្រឡងវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា /វិស្វកម្ម របស់ថ្នាក់វិទ្យាល័យនោះទេ ។ ការរាយការណ៍ទាំងអស់ពីលទ្ធផលផ្លូវការ នឹងធ្វើឡើងនៅ រដូវស្លឹកឈើជ្រុះឆ្នាំ 2007 សម្រាប់ការប្រឡងវិទ្យាសាស្ត្រថ្នាក់វិទ្យាល័យនិទាឃរដូវឆ្នាំ 2007 ។

### សំណួរសាកល្បង

សិស្សថ្នាក់ទី 5 , ទី 7 , ទី 10 និង ទី 11 បានចូលរួមក្នុងសំណួរសាកល្បងប្រវត្តិសាស្ត្រ និង វិទ្យាសាស្ត្រសង្គម ។ គ្មានលទ្ធផលរបស់សិស្ស សាលារៀន ឬ មណ្ឌលត្រូវបានរាយការណ៍សម្រាប់សំណួរសាក ល្បងឡើយ ។

### ការប្រឡងសាជាថ្មី

នៅរដូវស្លឹកឈើជ្រុះ និង រដូវផ្ការីកម្តងៗ ក្រសួងនឹងផ្តល់ឱកាសឱ្យសិស្សថ្នាក់ទីដប់មួយ និង ទីដប់ពីរ ព្រមទាំងយុវជនដែលនៅក្រៅសាលា ដើម្បីចូលរួម MCAS Retests [ ប្រឡង MCAS ម្តងទៀត ] ។ សិស្សទាំងអស់ដែលសិក្សានៅឆ្នាំសិក្សា 2003-2006 ដែលមិនទាន់បានទទួល Competency Determination [ ការអនុម័តថាមានសមត្ថភាព ] អាចមានសិទ្ធិចូលរួមប្រឡង MCAS ក្នុងវិស័យ ELA និង ការប្រឡងគណិតសាស្ត្រសាជាថ្មីក្នុងកំឡុងឆ្នាំកន្លងទៅ ។

សិស្សថ្នាក់ទីដប់មួយដែលព្យាយាមធ្វើឱ្យពិន្ទុក្នុងការប្រឡង MCAS បានប្រសើរជាងមុន ដើម្បីឱ្យមាន សិទ្ធិបានទទួល Certificate of Mastery [ សញ្ញាបត្រចេះដឹង ] ត្រូវបានអនុញ្ញាតឱ្យចូលរួមប្រឡងតាម មាត្រាដ្ឋាន MCAS ឆ្នាំ 2006 ថ្នាក់ទី 10 នៃ ELA និង ការប្រឡងគណិតសាស្ត្រ ។ សិស្សថ្នាក់ទី 11 ផ្សេងទៀត ដែលអវត្តមានត្រូវបានកត់ត្រាទុកដោយសារសុខភាពសម្រាប់ការប្រឡងថ្នាក់ទី 10 ឬ ដែលត្រូវបានផ្ទេរទៅកាន់សាលារដ្ឋនៃរដ្ឋម៉ាស្សាឈូសិតបន្ទាប់ពីថ្នាក់ទី 10 ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុង ការប្រឡង MCAS ថ្នាក់ទី 10 ឆ្នាំ 2006 តាមបទដ្ឋាន ដើម្បីព្យាយាមបំពេញលក្ខណៈសម្បត្តិសម្រាប់ John and Abigail Adams Scholarship [ អាហារូបករណ៍ John and Abigail Adams ] ។

## III. *តើសំណួរប្រភេទអ្វីខ្លះដែលមាននៅក្នុងការប្រឡង MCAS ?*

ការប្រឡង **MCAS** ប្រើទ្រង់ទ្រាយសំណួរច្រើនយ៉ាង ដើម្បីប៉ាន់ប្រមាណពីការសិក្សារបស់សិស្ស ។

- **Multiple-choice questions [ សំណួរ-រើសចម្លើយ ]** ត្រូវបានប្រើនៅក្នុងសំណួរគ្រប់មុខវិជ្ជា លើកលែងតែផ្នែកតែងសេចក្តី (ELA) ។ សិស្សរើសចម្លើយត្រូវ ក្នុងចំណោមចម្លើយផ្តល់ឱ្យទាំងបួន ។

  ចម្លើយត្រូវគឺបានផ្តល់ឱ្យពិន្ទុ 1 និង ចម្លើយខុសគឺបានផ្តល់ឱ្យពិន្ទុ 0 ។

- **Open-response questions [ សំណួរ-ចម្លើយចំហរ ]** ត្រូវបានប្រើនៅក្នុងសំណួរគ្រប់មុខវិជ្ជា លើកលែងតែការប្រឡងតែងសេចក្តី (ELA) ។ យោងទៅតាមមុខវិជ្ជាដែលបានប្រឡងនោះ សិស្សបង្កើត–ចម្លើយដោយសរសេរ ដែលមានតែមួយវគ្គ ឬ ច្រើនវគ្គ និង/ឬ គូសផែនទី តារាង ឌីយ៉ាក្រាម គូសរូបភាពសម្រាប់ពន្យល់ ឬ គំនូសតាង ។

  សម្រាប់គណិតវិទ្យាថ្នាក់ទី 3 ចម្លើយនិមួយៗទទួលពិន្ទុពី 0-2 ផ្អែកតាមការណែនាំផ្តល់ពិន្ទុ ។ សម្រាប់ថ្នាក់ផ្សេងទៀត និង គ្រប់មុខវិជ្ជាទាំងអស់ ចម្លើយនិមួយៗទទួលពិន្ទុពី 0-4 ផ្អែកតាមការណែនាំផ្តល់ពិន្ទុសំណួរចម្លើយចំហរ ។

- **Short-answer questions [ សំណួរ-ចម្លើយខ្លី ]** ត្រូវបានប្រើនៅតែក្នុងសំណួរខាងគណិតសាស្ត្រប៉ុណ្ណោះ ។ សិស្សបញ្ចេញចម្លើយខ្លី តាមធម្មតាចម្លើយជាលេខ ឬ សេចក្តីថ្លែងខ្លីមួយ ។

  ចម្លើយត្រូវគឺបានពិន្ទុ 1 និង ចម្លើយខុសគឺបានពិន្ទុ 0 ផ្អែកតាមការណែនាំផ្តល់ពិន្ទុ ។

- **Writing prompts [ តែងសេចក្តីតាមប្រធានផ្តល់ឱ្យ ]** មាននៅផ្នែកតែងសេចក្តីអក្សរសិល្ប៍អង់គ្លេស (ELA) ។ នៅគ្រប់កម្រិតថ្នាក់ឱ្យប្រឡង សិស្សសរសេរតែងសេចក្តីឆ្លើយតបតាមប្រធានដែលសរសេរផ្តល់ឱ្យ ។

  ការប្រឡងតែងសេចក្តីអក្សរសិល្ប៍អង់គ្លេស (ELA) បានឱ្យធ្វើពីរពេលក្នុងថ្ងៃតែមួយ ដោយបានសម្រាកបន្តិចរវាងពេលទាំងពីរ ។ ពេលទីមួយ សិស្សសរសេររៀបចំព្រាងជាដំបូង ដែលមិនទាន់ឱ្យពិន្ទុឆ្លើយតបតាមប្រធានដែលបានផ្តល់ឱ្យនៃការសរសេររបស់គេ ។ បន្ទាប់ពីសម្រាក សិស្សត្រឡប់មកដើម្បីកែការសរសេរព្រាងទៅជាការបញ្ចប់នៃការសរសេរតែងសេចក្តី ហើយប្រគល់ទៅឱ្យមេប្រយោគដើម្បីឱ្យពិន្ទុ ។

  ការសរសេរតែងសេចក្តីអក្សរសិល្ប៍អង់គ្លេស (ELA) និមួយៗទទួលពិន្ទុពីរវិស័យដូចខាងក្រោមតាមលំនាំក្នុងក្បួនឱ្យពិន្ទុ :

  - Topic Development [ រៀបរាប់តាមប្រធាន ] (ពិន្ទុ 2 ទៅ 12)
  - Standard English Conventions [ ប្រើក្បួនខ្នាតភាសាអង់គ្លេស ] (ពិន្ទុ 2 ទៅ 8 )

## IV. *តើគេនឹងប្រើប្រាស់លទ្ធផលប្រឡងរបស់កូនខ្ញុំយ៉ាងដូចម្តេច ?*

- នៅពេលលោក–អ្នកពិនិត្យមើលលទ្ធផលរបស់កូនលោក–អ្នក សូមចងចាំចំណុចខាងក្រោមនេះ : រៀនសូត្ររបស់កូនលោក–អ្នក នៅក្នុងមុខវិជ្ជាដែលសួរក្នុងពេលប្រឡង MCAS នៅឆ្នាំ 2006 ។ សូមប្រើប្រាស់លទ្ធផលពីការប្រឡង MCAS រួមគ្នាជាមួយការវាយតម្លៃរបស់គ្រូ និង កិច្ចការធ្វើនៅសាលារៀនពីមួយថ្ងៃទៅមួយថ្ងៃរបស់កូនលោក–អ្នក ដើម្បីប៉ាន់ប្រមាណថាតើកូនលោក–អ្នកធ្វើកិច្ចការបានល្អយ៉ាងណានៅសាលារៀន ។ ចំណាប់អារម្មណ៍ និង ការលើកទឹកចិត្តរបស់លោក–អ្នក គឺមានសារៈសំខាន់ណាស់ ។

- របាយការណ៍សម្រាប់មាតាបិតា និង អាណាព្យាបាល ស្តីពី MCAS របស់កូនលោក–អ្នក ត្រូវ បានចាត់ទុកថាជាផ្នែកនៃសំណុំរឿងសិស្សបណ្តោះអាសន្នរបស់កូនលោក–អ្នក ។ សំណុំរឿង សិស្សបណ្តោះអាសន្នរបស់កូនលោក–អ្នក រួមមាននូវព័ត៌មានទាំងអស់ដែលកត់ចុះក្នុងសំណុំប្រវត្តិរៀនសូត្រដែលសាលារក្សាទុកអំពីកូនលោក–អ្នក ដែលមាននៅក្នុងសៀវភៅសិក្ខាគារិករបស់គេទេ ។ ជាទូទៅ សំណុំរឿងសិស្សទាំងនេះ មិនអាចពិនិត្យមើលបានដោយនរណាម្នាក់ ក្រៅពីសិស្ស មាតាបិតា ឬ អាណាព្យាបាល និង បុគ្គលិកសាលារៀនដែលមានការអនុញ្ញាត ដោយគ្មានការយល់ព្រមពីមាតាបិតា ឬ អាណាព្យាបាលសិស្សបានឡើយ ។ គេនឹងកំទេចចោលសំណុំរឿងបណ្តោះអាសន្នរបស់សិស្សនៅពេលមិនយូរជាងប្រាំឆ្នាំ បន្ទាប់ពីពេលដែលសិស្សប្តូរសាលា ប្រឡងជាប់បានសញ្ញាប័ត្រ ឬ ក៏ចាកចេញពីប្រព័ន្ធសាលារៀន។ ដើម្បីបានព័ត៌មានបន្ថែមអំពីរឿងនេះ សូមមើលវ៉ិបសាយរបស់ក្រសួងសិក្សាធិការតាមអាសយដ្ឋាន www.doe.mass.edu ។

- សិស្សថ្នាក់ទី 10 ត្រូវតែប្រឡង MCAS ឱ្យជាប់វិស័យវិជ្ជាអក្សរសិល្ប៍អង់គ្លេស (ELA) និង គណិតសាស្ត្រដែលតម្រូវដើម្បីឱ្យបានសញ្ញាប័ត្រមធ្យមសិក្សា ។ បន្ថែមពីលើការប្រឡង MCAS ឱ្យជាប់ សិស្សានុសិស្សត្រូវបំពេញសេចក្តីតម្រូវនៃតំបន់ ដើម្បីឱ្យបានសញ្ញាប័ត្រមធ្យម សិក្សា ។ បើកូនលោក–អ្នកមិនបានពិន្ទុ 220 ឬច្រើនជាងនៅពេលប្រឡង MCAS វិស័យ អក្សរសិល្ប៍អង់គ្លេស (ELA) និង/ឬគណិតសាស្ត្រ កូនរបស់លោក–អ្នកនឹងត្រូវប្រឡងឡើងវិញ ឬ ការប្រឡងដែលមិនជាប់ ។ សិស្សមានឱកាសច្រើនដង ដើម្បីប្រឡងសាជាថ្មីក្នុងវិស័យវិជ្ជា ដែលខ្លួនមិនទាន់បានប្រឡងជាប់ ។ បើកូនរបស់លោក–អ្នកធ្លាក់ការប្រឡង

MCAS ថ្នាក់ទី 10 តែមួយ ឬ ទាំងពីរ លោក–អ្នកនឹងទទួលភ្ជាប់ជាមួយនូវ *របាយការណ៍សម្រាប់មាតាបិតា និង អាណាព្យាបាល*នូវការជូនដំណឹងជាលាយលក្ខណ៍អក្សរ ពីតម្រូវការសិទ្ធិទទួលបានការដាក់ Performance Appeal [ បណ្តឹងអនុវត្ត ] ។

- លទ្ធផល ELA និង គណិតសាស្ត្រពីសិស្សរៀនថ្នាក់ទី 10 និង សម្រាប់សិស្សថ្នាក់ទី 11 ដែលពុំបានចូលរួមពីមុននៅថ្នាក់ទី 10 នៃ ELA និង/ឬការប្រឡងគណិតសាស្ត្រ ក៏ត្រូវបានប្រើដើម្បី សម្រេចពីសិទ្ធិទទួលសម្រាប់ប្រាក់ជំនួយផ្តល់ឱ្យនិស្សិតពី John និង Abigail Adams ជាស្វ័យប្រវត្តិ សិស្សរៀននៅមធ្យមសិក្សារដ្ឋនៃរដ្ឋម៉ាស្សាឈូសិត មានគុណសម្បត្តិសម្រាប់ប្រាក់ជំនួយផ្តល់ឱ្យនិស្សិតពី Adams ការទទួលប្រាក់ជំនួយ បើសិនជាគេ :

    1. បានពិន្ទុផ្នែក *Advanced [ជឿនលឿន]* ក្នុងមួយណាក៏បាន ជាថ្នាក់ទី 10 នៃ ELA ឬ ជា គណិតសាស្ត្រ

    2. បានពិន្ទុផ្នែក *Proficient [ចេះគ្រប់គ្រាន់]* ឬ *Advanced [ជឿនលឿន]* ក្នុងមុខវិជ្ជាទីពីរ (ELA ឬជា គណិតសាស្ត្រ ) និង

    3. បានពិន្ទុ MCAS រួមគ្នានៅលើការប៉ាន់ប្រមាណដែលចាត់ជាថ្នាក់ក្នុងផ្នែកខាងលើ 25 ភាគរយនៅក្នុងសាលារៀនមណ្ឌលរបស់គេ

- ក្រុមអ្នកអប់រំ ប្រើលទ្ធផលរបស់សិស្ស សាលា និង តំបន់ ដ៏ច្រើនសន្ធឹកសន្ធាប់នេះ ដើម្បីពិនិត្យមើលឡើងវិញនូវកម្មវិធី និងការបង្ហាត់បង្រៀន និងគំរោងការណ៍សម្រាប់ធ្វើឱ្យល្អប្រសើរ ។ នេះជាផ្នែកមួយនៃការបំពេញគោលបំណងនៃច្បាប់កែទម្រង់ការសិក្សា ដែលមានបំណងធ្វើឱ្យការបង្ហាត់បង្រៀនឱ្យរឹតតែល្អប្រសើរ និងការរៀនបាន សម្រេចជោគជ័យនៃសិស្សានុសិស្ស រៀននៅរដ្ឋម៉ាស្សាឈូសិត ដោយយោងទៅតាមលក្ខខណ្ឌរៀន សូត្រនៃគំរោងកម្មវិធីសិក្សា ។

- តំបន់ទាំងឡាយណាដែលមានសិស្សចំនួនច្រើនជាង 20 បានពិន្ទុ ដែលចាត់ថាជាកម្រិតសិក្សា *Warning/Failing [ព្រមាន/ធ្លាក់]* ក្នុងការប្រឡង MCAS ទោះជា MCAS ELA ឬ គណិតសាស្ត្រនៅកម្រិតថ្នាក់ណាមួយ គឺតម្រូវឱ្យធ្វើ Individual Student Success Plans [ គំរោងធ្វើឱ្យមានជោគជ័យសម្រាប់សិស្សម្នាក់ៗ ] សម្រាប់សិស្សទាំងអស់ណាដែលបានពិន្ទុកម្រិតនោះ ។ ក្រុមអ្នកអប់រំ នៅតំបន់ទាំងនោះ ប្រើលទ្ធផលនៃការប្រឡងរបស់សិស្សជាមួយនឹងព័ត៌មានប៉ាន់ប្រមាណការចេះដឹងផ្សេងទៀត ដើម្បីបង្កើតគំរោងដែលផ្តល់នូវចំណុចសំខាន់ទាំងអស់នៃ ការគាំទ្របន្ថែម និង ការបម្រើរាប់បញ្ចូលទាំង Academic Support Programs [ កម្មវិធីគាំទ្រការសិក្សាយកមុខវិជ្ជា ] ដែលផ្តល់ចំពោះសិស្សដើម្បីជួយឱ្យបានជោគជ័យក្នុងការចេះដឹងតាមមាត្រដ្ឋានរៀនសូត្ររបស់រដ្ឋ ។

- ក្រសួងសិក្សាធិការ ប្រើលទ្ធផល MCAS ដើម្បីស្ទង់ពីការចម្រើនលូតលាស់នៃសាលារៀន ប្រយោជន៍ឱ្យសិស្សទាំងអស់បានសម្រេចក្នុងភាពជំនាញផ្នែកអក្សរសិល្ប៍អង់គ្លេស (ELA) និង គណិតសាស្ត្រ ។ ការសម្រេចជោគជ័យក្នុងគោលបំណងនេះនៅឆ្នាំ 2014 គឺជាគោលដៅ យ៉ាងសំខាន់នៃច្បាប់រដ្ឋសហព័ន្ធ ដែលចែងថាមិនត្រូវទុកឱ្យកុមារណារៀននៅក្រោយកម្មវិធីឡើយ ។ រៀងរាល់ឆ្នាំ រដ្ឋបញ្ចេញផ្សាយការសម្រេចពី Adequate Yearly Progress [ ការចម្រើនលូតលាស់គ្រប់គ្រាន់ប្រចាំឆ្នាំ ] (AYP) សម្រាប់សិស្សសរុបចំនួនទាំងអស់ក្នុងរដ្ឋ និង សម្រាប់សិស្សទាំងអស់ក្នុងមណ្ឌលនិមួយៗ និង សិស្សក្នុងក្រុមតូចៗនៅតាមសាលានិមួយៗ និង តាមមណ្ឌល ។ សិស្សក្នុងក្រុមតូចៗរាប់ទាំង :

    - សិស្ស ឬអតីតសិស្សមានជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់

    - សិស្សដែលរៀនធ្លាក់

    - សិស្សដែលមានចំណូលទាប

    - សិស្សអាហ្វ្រិកអាមេរិកកាំង/ស្បែកខ្មៅ សិស្សអាស៊ី សិស្សអេស្ប៉ាញ៉ុល សិស្សជនជាតិដើមអាមេរិកកាំង សិស្សស្បែកស

## V. តើលទ្ធផលនៃ MCAS រាយការណ៍យ៉ាងដូចម្តេច ?

### ក. ពិន្ទុរបស់កូនលោក-អ្នក

ផ្នែកទី I នៃរបាយការណ៍សម្រាប់មាតាបិតា និងអាណាព្យាបាល រាយបង្ហាញពីមុខវិជ្ជាប្រឡងតាមថ្នាក់របស់កូនលោក–អ្នក កម្រិតពិន្ទុកូនរបស់លោក–អ្នក ក្នុងមុខវិជ្ជានិមួយៗ ពិន្ទុកូនរបស់លោក–អ្នក ក្នុងមុខវិជ្ជានិមួយៗ និងលំដាប់ពិន្ទុប្រហាក់ប្រហែល ។

### កម្រិតលទ្ធផលនៃការប្រឡង

កម្រិតលទ្ធផលនៃការប្រឡងបង្ហាញលទ្ធផល ដែលសិស្សធ្វើបានទៅតាមនឹងលក្ខខណ្ឌរៀនសូត្រក្នុងគំរោងកម្មវិធីសិក្សា ។ ដើម្បីរាយការណ៍លទ្ធផលនៃការប្រឡង ដែលប្រើកម្រិតនៃលទ្ធផលរបៀប MCAS គ្រូបង្រៀនតាមថ្នាក់ អ្នកអប់រំក្នុងក្រសួង សាស្ត្រាចារ្យឧត្តមសិក្សា និងប្រជាពលរដ្ឋនៅក្នុងសហគមន៍បានចូលរួមជាគណៈកម្មាធិការតែងតាំងមាត្រដ្ឋាន សម្រាប់ការប្រឡងថ្មីនីមួយៗ ដើម្បីសំគាល់អំពីពិន្ទុប្រឡងសរុបដែលទាបបំផុត ជាប់ទាក់ទងជាមួយនឹងកម្រិតការបំពេញសិក្សានិមួយៗ ។

របាយការណ៍សម្រាប់មាតាបិតា និង អាណាព្យាបាលមិនមានផ្តល់ជូនសម្រាប់សំណួរសាកល្បងឡើយ ឬ ការប្រឡងពិសោធន៍មើលអំពីវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា/វិស្វកម្មឡើយ ។ លទ្ធផលនៃសំណួរសាកល្បង គឺមិនបានរាយការណ៍ ប៉ុន្តែត្រូវបានប្រើដើម្បីផ្តល់ព័ត៌មានជាប់ទាក់ទងការបំពេញកិច្ចការនៃសំណួរប្រឡង ។

លទ្ធផលការវិភាគមុខវិជ្ជាដែលប្រឡង ចេញពីការប្រឡងពិសោធន៍មើលអំពីវិទ្យាសាស្ត្រ និងបច្ចេក វិទ្យា/វិស្វកម្មថ្នាក់វិទ្យាល័យ គឺបានផ្តល់ទៅសាលារៀនទាំងឡាយ ហើយមានសម្រាប់ជូនមាតាបិតាតាមសំណូមពរ ។

ពីថ្នាក់ទី 4 រហូតដល់ថ្នាក់ទី 8 គេរាយការណ៍លទ្ធផល MCAS ដោយអនុលោមទៅតាមកម្រិតសិក្សាបួន យ៉ាង : ***Advanced [ ជឿនលឿន ] Proficient [ ជំនាញ ] Needs Improvement [ ខំរៀនថែម ទៀត ]*** និង ***Warning [ ព្រមាន ]*** ។ សម្រាប់ការប្រឡងឡើងថ្នាក់ទី 10 ELA និង គណិតសាស្ត្រ និង សម្រាប់ការប្រឡងឡើងវិញ នោះកម្រិតសិក្សាមាន *ជឿនលឿន ជំនាញ ខំរៀនថែមទៀត* និង ***Failing [ ធ្លាក់ ]*** ។ សម្រាប់ការប្រឡងអាន និង គណិតសាស្ត្រថ្នាក់ទី 3 កម្រិតលទ្ធផលនៃការប្រឡងគឺ ***Above Proficient [ លើសពីជំនាញ ] ខំរៀនថែមទៀត*** និង ***ព្រមាន*** ។

ការវាយតម្លៃជម្រើសរបស់ MCAS សម្រាប់សិស្សថ្នាក់ទី 3-8 និងទី 10 ក៏មានកម្រិតលទ្ធផលនៃ ការប្រលង ***Progressing [ រីកចម្រើន ] Emerging [ កើនឡើង ]*** និង ***Awareness [ ចេះ ]*** ។

ផ្នែកខាងក្រោយនៃ *របាយការណ៍សម្រាប់មាតាបិតា និងអាណាព្យាបាល* ផ្តល់នូវនិយមន័យទូទៅនៃកម្រិតលទ្ធផលនៃការប្រឡងរបស់ MCAS និង ការវាយតម្លៃជម្រើសរបស់ MCAS ។

### មាត្រដ្ឋានពិន្ទុ

សម្រាប់ថ្នាក់ទី 4-10 លំដាប់មាត្រដ្ឋានពិន្ទុរបស់សិស្សមានពី 200 ទៅ 280 ។ ការប្រើមាត្រដ្ឋានពិន្ទុ ជួយសម្រួលក្នុងការបកស្រាយលទ្ធផល MCAS ក្នុងចំណោមការប្រឡង និងឆ្នាំទាំងឡាយ ។ ឧទាហរណ៍ មាត្រដ្ឋានពិន្ទុ 240 នៃការប្រឡង MCAS វិស័យវិជ្ជាណាមួយ ចង្អុលឱ្យឃើញជានិច្ចថា ពិន្ទុរបស់សិស្សឋិតនៅក្រោមកម្រិតការបំពេញសិក្សា *ភាពជំនាញ* ។ មិនមានមាត្រដ្ឋានពិន្ទុសម្រាប់ សិស្សថ្នាក់ទី 3 នោះទេ ។

| រង្វង់មាត្រដ្ឋានពិន្ទុនៃការប្រឡង MCAS ឆ្នាំ 2006 ថ្នាក់ទី 4-10 | |
|---|---|
| កម្រិតការបំពេញសិក្សា | មាត្រដ្ឋានពិន្ទុ |
| *ជឿនលឿន* | 260 – 280 |
| *ជំនាញ* | 240 – 258 |
| *ត្រូវខំរៀនថែមទៀត* | 220 – 238 |
| *ព្រមាន* (ថ្នាក់ទី 4 ទៅទី 8)<br>*ធ្លាក់* (ថ្នាក់ទី 10) | 200 – 218 |

## ពិន្ទុសុទ្ធ

ពិន្ទុសុទ្ធត្រូវបានបង្ហាញក្នុងផ្នែក Display of Scores and Probable Range of Scores [ ការបង្ហាញពី ពិន្ទុ និង លំដាប់ពិន្ទុនៃរបាយការណ៍ ] ។ ពិន្ទុសុទ្ធសរុបតំណាងចំនួនពិន្ទុដែល កូនរបស់លោក–អ្នកបានទទួលក្នុងការប្រឡង ។

## ការបង្ហាញពីពិន្ទុ និង លំដាប់ពិន្ទុ

ចំណែកនៃផ្នែកទី I នេះបង្ហាញពីពិន្ទុនៃកូនរបស់លោក–អ្នក និងជួរកម្រិតនៃពិន្ទុដែលអាចនឹងមាន ដោយប្រើសញ្ញាគំនូសឆ្នូតពណ៌ប្រផេះ ដែលមានបន្ទាត់បញ្ឈរនៅចំកណ្តាល ។ បន្ទាត់បញ្ឈរតំណាង រង្វង់មាត្រដ្ឋានពិន្ទុនៃកូនរបស់លោក–អ្នក (ឬ ពិន្ទុសុទ្ធសម្រាប់ថ្នាក់ទី 3) ក្នុងការប្រឡងនិមួយៗ ។ សញ្ញាចម្រឹងផ្តេកបង្ហាញរង្វង់ពិន្ទុដែលកូនរបស់លោក–អ្នកប្រហែល នឹងទទួល បើកូនលោក–អ្នកប្រឡងច្រើនដង ។ លំដាប់ពិន្ទុក៏ត្រូវបានបង្ហាញពាក់ព័ន្ធនឹងកម្រិតពិន្ទុ MCAS ផងដែរ ។

## ខ. *ផ្នែកទី II : (ថ្នាក់ទី 4 ទី 7 និង ទី 10) យោបល់ស្តីពីការបំពេញកិច្ចការផ្នែកសរសេររបស់កូនលោក–អ្នក*

សិស្សថ្នាក់ទី 4 ទី 7 ទី 10 ដែលបានដាក់ឱ្យប្រឡងតែងសេចក្តី ការសរសេរ និងភាសា ព្រមទាំងការប្រឡងភាសាអង់គ្លេស (ការអាន) ។ លទ្ធផលការប្រឡងទាំងពីរផ្នែក ត្រូវបានគេដាក់បញ្ចូលគ្នា ដើម្បីធ្វើសម្រេចអំពីកម្រិតសិក្សា និង មាត្រាដ្ឋានពិន្ទុអក្សរសិល្ប៍អង់គ្លេស ។ សម្រាប់ថ្នាក់ទាំងនេះ ផ្នែកទី II នៃរបាយការណ៍សម្រាប់មាតាបិតា និង អាណាព្យាបាល ចុះរាយយោបល់អ្នកឱ្យពិន្ទុអំពីការប្រឡងតែងសេចក្តី ។

ការតែងសេចក្តីអក្សរសិល្ប៍អង់គ្លេស ELA របស់កូនលោក–អ្នក ត្រូវបានឱ្យពិន្ទុដោយឡែកពីគ្នានៃអ្នកឱ្យ ពិន្ទុពីរនាក់ ។ អ្នកឱ្យពិន្ទុនិមួយៗបានទទួលបញ្ជីមួយ នៃយោបល់ដែលអាចមាននៃការសរសេររបស់សិស្ស និង ជ្រើសរើសយោបល់ចំនួនពីរ ចេញពីបញ្ជីនេះ ដើម្បីផ្តល់ជូនលោក–អ្នកនូវមតិឆ្លើយតបស្តីពីការបំពេញកិច្ចការសរសេររបស់កូនលោក–អ្នក ។ បើអ្នកឱ្យពិន្ទុទាំងពីរជ្រើសរើសយកយោបល់ដូចគ្នានោះវាត្រូវបានសរសេរចុះតែម្តងប៉ុណ្ណោះ ។ បញ្ជីយោបល់យ៉ាងពេញលេញ ដែលអាចមានពីអ្នកឱ្យពិន្ទុ គឺមានដាក់ជូននៅលើវ៉ិបសាយរបស់ក្រសួងតាមអាសយដ្ឋាន www.doe.mass.edu/mcas/student/2005/scoring4.doc
www.doe.mass.edu/mcas/student/2005/scoring7.doc
www.doe.mass.edu/mcas/student/2005/scoring10.doc .

## គ. ផ្នែកទី III : ព័ត៌មានពីពិន្ទុរបស់កូនលោក-អ្នកចំពោះសំណួរសាកល្បងរបស់ MCAS

ផ្នែកទី III នៃរបាយការណ៍សម្រាប់មាតាបិតា និង អាណាព្យាបាល បង្ហាញពីវិធីដែលកូនលោក–អ្នកឆ្លើយរាល់សំណួរសាកល្បងក្នុងមុខវិជ្ជានិមួយៗដែលប្រឡង ។ ជួរទីមួយនៃផ្នែកនេះ រាយបង្ហាញពីលេខ ឬ អក្សរកាត់សម្រាប់សំណួរដែល អាចមាននិមួយៗ ។ តារាងខាងក្រោមនេះ បង្ហាញពីចំនួនសំណួរ សម្រាប់ថ្នាក់និមួយៗ និង មុខវិជ្ជានិមួយៗ ។

| ការប្រឡង MCAS ឆ្នាំ 2006<br>ចំនួនសំណួរទូទៅសម្រាប់ថ្នាក់និមួយៗ និង មុខវិជ្ជានិមួយៗ | | | |
|---|---|---|---|
| ថ្នាក់ | អក្សរសាស្ត្រអង់គ្លេស | គណិតវិទ្យា | វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា/វិស្វកម្ម |
| 3 | 42 | 35 | -- |
| 4 | 40 បូក តែងសេចក្តី | 39 | -- |
| 5 | 40 | 39 | 39 |
| 6 | 40 | 39 | -- |
| 7 | 40 បូក តែងសេចក្តី | 39 | -- |
| 8 | 40 | 39 | 39 |
| 10 | 40 បូក តែងសេចក្តី | 42 | -- |

ដោយសារតែចំនួនសំណួរមានខុសគ្នាពីថ្នាក់មួយ និងមុខវិជ្ជាមួយទៅមួយទៀត របាយការណ៍របស់កូនលោក–អ្នកនឹងមាននូវចំណាត់ថ្នាក់រាយការណ៍ និង ចន្លោះពិន្ទុដែលមានដោយផ្អែកតាមចំនួន និង ប្រភេទសំណួរក្នុងការប្រឡង ។ ឧទាហរណ៍ មានតែរបាយការណ៍ដែលមានអក្សរសាស្ត្រអង់គ្លេសថ្នាក់ទី 4 ទី 7 ឬទី 10 នឹងមាននូវព័ត៌មានដែលស្ថិតក្រោមអក្សរកាត់ ចំនួនសំណួររបស់ WP ។ ចន្លោះនេះនឹងត្រូវមានសម្រាប់រាល់ថ្នាក់ និងមុខវិជ្ជាទាំងអស់ ។

ចំណងជើង ដែលមាននៅទំព័រខាងក្រោយរបាយការណ៍សម្រាប់មាតាបិតា និងអាណាព្យាបាលផ្តល់នូវព័ត៌មានពីការបកស្រាយ លេខកូដដែលប្រើប្រាស់ក្នុងចំណាត់ថ្នាក់រាយការណ៍ និងជួរពិន្ទុ ។ ដើម្បី មើលសំណួរពិតប្រាកដ និង ចម្លើយត្រឹមត្រូវ សូមចូលទៅកាន់វ៉ិបសាយរបស់ក្រសួង www.doe.mass.edu/mcas/testitems.html ដែលលោក–អ្នកនឹងរកឃើញនូវ *Release of Spring 2006 MCAS Test Items [ ការបញ្ចេញផ្សាយមុខវិជ្ជាឱ្យប្រឡងនារដូវផ្ការីកឆ្នាំ 2006 របស់ MCAS ]* ។ សម្ភារៈពីឯកសារនេះអាចជ្រើសរើស និង បោះពុម្ពចេញដោយកម្រិតថ្នាក់ និង មុខវិជ្ជានិមួយៗ។

## ឃ. ផ្នែកទី IV : តើពិន្ទុរបស់កូនលោក-អ្នកប្រៀបធៀបទៅនឹងពិន្ទុសាលា មណ្ឌល និងរដ្ឋយ៉ាងដូចម្តេចដែរ ?

ផ្នែកនៃរបាយការណ៍សម្រាប់មាតាបិតា និងអាណាព្យាបាលនេះ ប្រៀបធៀបការសិក្សារបស់កូនលោក–អ្នកក្នុងការប្រឡងវិស័យមុខវិជ្ជានិមួយៗ ជាមួយមធ្យមភាគនៃការសិក្សារបស់សិស្សរៀនថ្នាក់ដូច គ្នានៅសាលារៀនរបស់កូនលោក–អ្នកនៅសាលា មណ្ឌល តំបន់របស់កូនលោក–អ្នក និងនៅរដ្ឋទូទៅ។

កម្រិតការសិក្សារបស់កូនលោក–អ្នកពីផ្នែកទី I ត្រូវបានបង្កើតនៅផ្នែកខាងឆ្វេងដៃនៃក្រាហ្វនិមួយៗ (A = ជឿនលឿន , P+ = លើជំនាញ [ សម្រាប់តែថ្នាក់ទី 3 ] , P = ជំនាញ , NI = ត្រូវខំរៀនថែម ទៀត , W = ព្រមាន , F = ធ្លាក់ [ សម្រាប់តែថ្នាក់ទី 10 ] ) ។ បន្ទាត់ត្រង់នៅកណ្តាលក្រាហ្វបង្ហាញពី ភាគរយសិស្សក្នុងសាលាកូនលោក–អ្នក (SCH) និង តំបន់ (DIS) និង ក្នុងរដ្ឋ (STA) ដែលអនុវត្តចំពោះកម្រិតការសិក្សានិមួយៗ ។

## ង. *តើមានន័យយ៉ាងដូចម្ដេច បើសិនរបាយការណ៍សម្រាប់មាតាបិតា និងអាណាព្យាបាល បញ្ជាក់ថា កូនខ្ញុំចូលរួមក្នុងការវាយតម្លៃជ្រើសរើស*

ប្រសិនបើកូនលោក-អ្នកទទួលយកការវាយតម្លៃជ្រើសរើស របាយការណ៍សម្រាប់មាតាបិតា និង អាណាព្យាបាល បង្ហាញពីកម្រិតការសិក្សា តែមិនមែនជាមាត្រដ្ឋានពិន្ទុសម្រាប់ការប្រឡងតាមបទដ្ឋាន នោះទេ ។ ព័ត៌មានលំអិតផ្សេងទៀតអំពីការសិក្សារបស់កូនលោក-អ្នកចំពោះការវាយតម្លៃជ្រើសរើស ត្រូវបានផ្ដល់ក្នុងរបាយការណ៍ផ្សេងទៀត សម្រាប់មាតាបិតា និងអាណាព្យាបាល ។

## ច. *ក្នុងលក្ខខណ្ឌបែបណាដែលកូនសិស្សមួយណា មិនបានទទួលពិន្ទុ MCAS ?*

- បើសិស្សម្នាក់ឈប់មិនបានមកប្រឡង ដោយមានសំបុត្រពេទ្យដោះសារ របាយការណ៍សម្រាប់មាតាបិតា និង អាណាព្យាបាល នឹងបង្ហាញពីកម្រិត *medically excused [ ព្យាបាលដែលបានដោះសារ ]* នោះ ។

- បើសិស្សឈប់មិនបានមកប្រឡង និងបង្កើតការប្រឡងដោយមិនមានការដោះសារជាឯកសារពេទ្យ របាយការណ៍សម្រាប់មាតាបិតា និងអាណាព្យាបាល នឹងបង្ហាញពីកម្រិត *absent [ អវត្តមាន ]* នោះ ។

- បើសិស្សជាសិស្សដែលមានជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់ (LEP) ដែលបានចុះឈ្មោះរៀន នៅសាលារៀនសហរដ្ឋអាមេរិកជាលើកដំបូងក្នុងកំឡុងឆ្នាំសិក្សា 2005-2006 របាយការណ៍សម្រាប់មាតាបិតា និង អាណាព្យាបាល នឹងបង្ហាញពីកម្រិត *LEP [ ជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់ ]* នោះ ។

- ក្នុងករណីមួយចំនួនតូច របាយការណ៍សម្រាប់មាតាបិតា និងអាណាព្យាបាល អាចបញ្ជាក់ថា កម្រិតការសិក្សាគឺ *Incomplete [ មិនពេញលេញ ]* ឬ *Transferred [ ផ្ទេរ ]* ចន្លោះអាចនឹងទំនេរ ។ ដើម្បីឱ្យបាន ព័ត៌មានថែមទៀត សូមទាក់ទងសាលារបស់កូនលោក-អ្នក ។

# VI. *តើខ្ញុំអាចរកព័ត៌មានថែមទៀតនៅឯណា ?*

## ក. *របាយការណ៍បន្ថែម ដែលមាននៅសាលានៃកូនរបស់លោក-អ្នក*

ប្រភពជំនួយដែលបានចុះរាយផ្នែកនេះ បានត្រូវផ្ដល់ទៅសាលានានា និងមណ្ឌល បន្ទាប់ពីបានដាក់ឱ្យប្រឡង MCAS ។ សូមទាក់ទងទៅសាលាដែលកូនលោក-អ្នកបានប្រឡង MCAS សម្រាប់ការទទួលប្រភពជំនួយទាំងនេះ ។

- ***Composition CD [ ថាសស៊ីឌីអត្ថបទតែងសេចក្ដី ]*** (សម្រាប់តែថ្នាក់ទី 4 ទី 7 និង ទី 10)
អត្ថបទតែងសេចក្ដីអក្សរសិល្ប៍ភាសាអង់គ្លេស **(ELA)** របស់សិស្ស ត្រូវបានបញ្ជូនទៅសាលារៀន ជាទ្រង់ទ្រាយអេឡិចត្រូនិកនៅក្នុងថាសស៊ីឌី ហើយមានផ្ដល់ជូនសម្រាប់មាតាបិតា និង អាណាព្យាបាលតាមសំណូមពរ ។

- ***School* and *District Reports [ របាយការណ៍សាលា* និង *តំបន់ ]***
របាយការណ៍ទាំងនេះ អាចមានតាមអ៊ិនធ័រណេត ផ្ដល់ព័ត៌មានអំពីក្រុមតូចៗនៃសិស្សដែលបានប្រឡងអំពីការចែករំលែកនៃលទ្ធផលតាមមាត្រដ្ឋានពិន្ទុមួយរយៈពេល និង លទ្ធផលកម្រិតការ សិក្សា និងការប្រៀបធៀបលទ្ធផលបីឆ្នាំ ។

- ***Test Item Analysis Report Summaries [ សេចក្ដីសង្ខេបរបាយការណ៍ការវិភាគមុខវិជ្ជាឱ្យប្រឡង ]***
របាយការណ៍ទាំងនេះ បង្ហាញពីចំណុចពិន្ទុជាមធ្យម និង ភាគរយនៃការឆ្លើយតបសរុបរបស់សិស្សសម្រាប់ចម្លើយជ្រើសរើសចម្លើយខ្លី ឬសំណួរចម្លើយចំហរកម្រិតពិន្ទុ ។

## ខ. *ប្រភពជំនួយផ្សេងទៀត*

ការបោះពុម្ពផ្សាយដែលមានចុះរាយក្នុងផ្នែកនេះ គឺមានដាក់ជូននៅលើវ៉ិបសាយរបស់ក្រសួង។ ឯកសារជាច្រើនក៏មាននៅឯសាលានៃកូនរបស់លោក-អ្នក ។

- *Release of Spring 2006 MCAS Test Items [ ការបញ្ចេញផ្សាយមុខវិជ្ជាឱ្យប្រឡងនារដូវផ្ការីកឆ្នាំ 2006 របស់ MCAS ]* អាចទទួលយកតាម www.doe.mass.edu/mcas/testitems.html មាន សំណួរក្នុងការប្រឡង MCAS ពីឆ្នាំ 2006 ដែលគេប្រើជាមូលដ្ឋានសម្រាប់លទ្ធផលរបស់សិស្ស

- *Requirements for the Participation of Students with Disabilities (Spring 2006 Update) [ សេចក្តីតម្រូវក្នុងការចូលរួមនៃសិស្សដែលរៀនធ្លាក់ (ការកែសម្រួលសម្រាប់រដូវផ្ការីកឆ្នាំ 2006) ]* ផ្តល់ចំណុចសំខាន់នៃសេចក្តីតម្រូវខាងការចូលរួម និង ការសម្របសម្រួលអនុញ្ញាតសម្រាប់សិស្សដែលរៀនធ្លាក់ ។

- *Requirements for the Participation of Students with Limited English Proficiency in MCAS and MEPA (Spring 2006 Update) [ សេចក្តីតម្រូវក្នុងការចូលរួមប្រឡងនៃសិស្សដែលមានភាពជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់ (LEP) ក្នុង MCAS និង MEPA (ការកែសម្រួលសម្រាប់រដូវផ្ការីកឆ្នាំ 2006) ]* អាចទទួលយកតាម www.doe.mass.edu/mcas/part_req.html ផ្តល់ចំណុច សំខាន់ ពីសេចក្តីតម្រូវសម្រាប់ការចូលរួមនៃសិស្សដែលមានភាពជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់ (LEP) ។

- *Curriculum Frameworks* in *English Language Arts, Mathematics, Science and Technology/Engineering*, and *History and Social Science [ គំរោងកម្មវិធីសិក្សាអំពី អក្សរសិល្ប៍អង់គ្លេស គណិតសាស្ត្រ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា* និង *ប្រវត្តិសាស្ត្រ និង វិទ្យាសាស្ត្រសង្គម ]* អាចទទួលយកតាម www.doe.mass.edu/Frameworks/current.html ពិពណ៌នាពីអ្វីៗដែលសិស្ស គួរដឹង ហើយអាចមានសមត្ថភាពធ្វើបានតាមកម្រិតថ្នាក់នានា ។

## គ. *តើខ្ញុំអាចធ្វើអ្វីដើម្បីជួយកូនខ្ញុំ ?*

ជំនួយរបស់លោក-អ្នកចំពោះកូន មានភាពសំខាន់ណាស់ក្នុងពេលឥឡូវនេះ និង ពេលអនាគត ក្នុងការសិក្សាខាងអាជីពរបស់គេ ។ នេះគឺជាពាក្យរំលឹកខ្លះៗ សម្រាប់ជួយរៀបចំកូនរបស់លោក-អ្នក ដើម្បីប្រឡង MCAS ក្រោយទៀត :

- និយាយជាមួយគ្រូៗរបស់កូនលោក-អ្នកឱ្យបានទៀងទាត់ ក្រែងលោក-អ្នកអាចធ្វើការអ្វីខ្លះនៅផ្ទះ ដើម្បីជួយកូនលោក-អ្នករៀននៅសាលា ។

- ធ្វើឱ្យប្រាកដថាកូនលោក-អ្នក ចូលដំណេកឱ្យបានគ្រប់គ្រាន់ បរិភោគបានត្រឹមត្រូវ ហើយទៅសាលារៀនឱ្យទាន់ពេលវេលាជារៀងរាល់ថ្ងៃ ។

- ពិភាក្សាជាមួយកូនរបស់លោក-អ្នក អំពីមុខវិជ្ជាណាដែលត្រូវការធ្វើឱ្យមានការជឿនលឿនថែមទៀត ហើយថាតើកូនរបស់លោក-អ្នកគិតថាតើមានការរីកចម្រើនឡើងដែរទេ ។ ប្រសិនបើមានចម្លើយថាមិនមាន លោក-អ្នកត្រូវតែសួររកហេតុផល ។

- សួរកូនលោក-អ្នកអំពីកិច្ចការសាលាដែលយកមកធ្វើនៅផ្ទះ ហើយត្រូវប្រគល់ឱ្យគ្រូវិញនៅពេលថ្ងៃស្អែក ឬសប្តាហ៍ក្រោយ ហើយធ្វើឱ្យប្រាកដថាកិច្ចការនោះបានធ្វើចប់សព្វគ្រប់ ។

- សួរនាំកូនរបស់លោក-អ្នក ឱ្យពន្យល់អំពីមុខវិជ្ជាដែលគេកំពុងតែរៀន ។ ការសន្ទនានេះ អាចជួយលោក-អ្នកឱ្យដឹងអំពីការវិវត្តន៍នៃការរៀនសូត្ររបស់កូនលោក-អ្នក ហើយជួយកូនរបស់លោក-អ្នកឱ្យចាំអំពីវិជ្ជាដែលគេបានរៀនសូត្រ ។

- បើសិនជាកូនលោក-អ្នកជាសិស្សដែលរៀនធ្លាក់ សួរគ្រូៗរបស់គេថាតើ MCAS អាចជួយដាក់កូនលោក-អ្នកទៅនឹងផែនការ IEP ឬក៏ 504 សមត្រឹមត្រូវជាយ៉ាងណាដែរ ។

- ជួយកូនលោក-អ្នកហាត់រៀនសំណួរការប្រឡង MCAS ហើយមើលសាឡើងវិញជាមួយគ្នា ដើម្បីឱ្យលោក-អ្នក និង កូនលោក-អ្នកអាចចេះដោយសេចក្តីសង្ឃឹម ។

Khmer Version